# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :.....៥១.....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់

- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ពីការផ្ទេរធនធានពីថវិកាជាតិរដ្ឋជូនមូលនិធិឃុំ សង្កាត់សម្រាប់ចិរវេលា០៥ (ប្រាំ)ឆ្នាំ ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ទំហំថវិកាដែលត្រូវផ្ទេរប្រចាំឆ្នាំជាភាគរយនៃចំណូលចរន្តថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ និងរូបមន្ត សន្ទស្សន៍នៃការបែងចែកមូលនិធិឃុំ សង្កាត់ និងកម្មវិធីនៃការផ្ទេរឥណទាន និងសាច់ប្រាក់ទៅឱ្យរដ្ឋបាលឃុំ សង្កាត់។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើរដ្ឋបាលឃុំ សង្កាត់ទាំងអស់នៅទូទាំងប្រទេស។

## ជំពូកទី២

## ការធ្វើហិរញ្ញប្បទាន ការបែងចែក ការប្រើប្រាស់ និង ការផ្ទេរធនធានមូលនិធិឃុំ សង្កាត់

**មាត្រា៤.-**

ត្រូវផ្ទេរពីថវិការដ្ឋទៅគណនីមូលនិធិឃុំ សង្កាត់សម្រាប់ចិរវេលា០៥ (ប្រាំ)ឆ្នាំ ដោយកំណត់ជាភាគរយ នៃចំណូលចរន្តថវិការដ្ឋដូចខាងក្រោម÷

- ឆ្នាំថវិកា២០១៩: ចំនួន ៣ភាគរយនៃចំណូលចរន្តថវិការដ្ឋ ដែលបានអនុម័តឆ្នាំ២០១៨
- ឆ្នាំថវិកា២០២០: ចំនួន ៣,១ភាគរយនៃចំណូលចរន្តថវិការដ្ឋ ដែលនឹងត្រូវបានអនុម័តឆ្នាំ២០១៩
- ឆ្នាំថវិកា២០២១: ចំនួន ៣,២ភាគរយនៃចំណូលចរន្តថវិការដ្ឋ ដែលនឹងត្រូវបានអនុម័តឆ្នាំ២០២០
- ឆ្នាំថវិកា២០២២: ចំនួន ៣,៣ភាគរយនៃចំណូលចរន្តថវិការដ្ឋ ដែលនឹងត្រូវបានអនុម័តឆ្នាំ២០២១
- ឆ្នាំថវិកា២០២៣: ចំនួន ៣,៤ភាគរយនៃចំណូលចរន្តថវិការដ្ឋ ដែលនឹងត្រូវបានអនុម័តឆ្នាំ២០២២

**មាត្រា៥.-**

ធនធានមូលនិធិសរុបដែលបានមកពីការចូលរួមរបស់ថវិការដ្ឋ ដូចដែលមានកំណត់ក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ ពីការចូលរួមជំនួយឥតសំណងពីដៃគូអភិវឌ្ឍន៍នានា ត្រូវបានបែងចែក និងជូនដំណឹងជាផ្លូវការដល់រដ្ឋបាលឃុំ សង្កាត់នីមួយៗ ដើម្បីឱ្យរដ្ឋបាលឃុំ សង្កាត់គ្រោងចំណូលពីការបែងចែកមូលនិធិឃុំ សង្កាត់

ការចូលរួមជំនួយឥតសំណងពីដៃគូអភិវឌ្ឍន៍នានា ព្រមទាំងគ្រោងចំណាយទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដែលត្រូវរៀបចំលម្អិតទៅតាមទម្រង់ ជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារនៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៦.-**

ការរៀបចំ និងការអនុម័តគម្រោងថវិការបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវអនុលោមទៅតាមកាលបរិច្ឆេទនៃប្រព័ន្ធថវិកាជាតិ។

គម្រោងថវិការបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវរៀបចំ និងស្នើសុំការបញ្ជាក់អនុលោមភាពដូចខាងក្រោម÷

- គម្រោងថវិការបស់រដ្ឋបាលឃុំ ត្រូវបញ្ជាក់អនុលោមភាពដោយអភិបាលនៃគណៈអភិបាលខេត្ត
- គម្រោងថវិការបស់រដ្ឋបាលសង្កាត់ចំណុះរដ្ឋបាលក្រុង ត្រូវដាក់បញ្ចូលទៅក្នុងគម្រោងថវិការដ្ឋបាលក្រុងហើយដែលត្រូវបញ្ជាក់អនុលោមភាពដោយអភិបាលនៃគណៈអភិបាលខេត្ត អមដោយប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គម្រោងថវិការបស់រដ្ឋបាលសង្កាត់ចំណុះរដ្ឋបាលរាជធានីត្រូវបញ្ជាក់ទទួលស្គាល់ដោយអភិបាលនៃគណៈអភិបាលរាជធានី។

**មាត្រា៧.-**

ការប្រើប្រាស់ធនធានមូលនិធិឃុំ សង្កាត់សរុបប្រចាំឆ្នាំនីមួយៗត្រូវបានកំណត់ទៅតាមលំដាប់លំដោយនៃអាទិភាពចំណាយដូចខាងក្រោម÷

ទី១- ចំណាយសរុបសម្រាប់ប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ

ទី២- ចំណាយសរុបសម្រាប់ប្រតិបត្តិការរដ្ឋបាលមិនឱ្យលើសពី១៧ភាគរយ នៃធនធានមូលនិធិឃុំ សង្កាត់ សរុប *ដក* ចំណាយសរុបសម្រាប់ប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ

ទី៣- ចំណាយសម្រាប់អភិវឌ្ឍន៍មូលដ្ឋាន ស្មើនឹងធនធានមូលនិធិឃុំ សង្កាត់សរុប *ដក* ចំណាយសរុបសម្រាប់ប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីភូមិ និងចំណាយសរុបសម្រាប់ប្រតិបត្តិការរដ្ឋបាល។

**មាត្រា៨.-**

ចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាល និងចំណាយសម្រាប់អភិវឌ្ឍន៍មូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់ត្រូវបានវិភាជទៅឱ្យរដ្ឋបាលឃុំ សង្កាត់នីមួយៗតាមការគណនាដោយផ្អែកលើរូបមន្ត និងសន្ទស្សន៍ដូចខាងក្រោម ÷

**ក- ចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាល÷**

- ចំនួន៣៥ភាគរយ ជាចំណែកស្មើគ្នាត្រូវបានបែងចែកក្នុងចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលឃុំ សង្កាត់នីមួយៗ និង
- ចំនួន៦៥ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនសមាជិកក្រុមប្រឹក្សារបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ។

ខ- ចំណាយសម្រាប់អភិវឌ្ឍន៍មូលដ្ឋាន÷

- ចំនួន៣០ភាគរយ ជាចំណែកស្មើគ្នាត្រូវបានបែងចែកក្នុងចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលឃុំ សង្កាត់នីមួយៗ
- ចំនួន៣០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនប្រជាពលរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ ដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ
- ចំនួន៣០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រដោយផ្អែកតាមទិន្នន័យរបស់ក្រសួងផែនការ និង
- ចំនួន១០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនភូមិរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងមហាផ្ទៃ។

**មាត្រា៩.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបោះផ្សាយអាណត្តិឧបត្ថម្ភធនជូនមូលនិធិឃុំ សង្កាត់ជា០៤ (បួន) លើក សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំតាមកម្មវិធីដូចខាងក្រោម÷

- លើកទី១ : ផ្ទេរ២៥ភាគរយនៃធនធានវិភាជន៍សរុបនៅដើមត្រីមាសទី១
- លើកទី២ : ផ្ទេរ២៥ភាគរយនៃធនធានវិភាជន៍សរុបនៅដើមត្រីមាសទី២
- លើកទី៣ : ផ្ទេរ២៥ភាគរយនៃធនធានវិភាជន៍សរុបនៅដើមត្រីមាសទី៣
- លើកទី៤ : ផ្ទេរ២៥ភាគរយនៃធនធានវិភាជន៍សរុបនៅដើមត្រីមាសទី៤

**មាត្រា១០.-**

ការអនុវត្តថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។ ចំពោះគម្រោង ឬកម្មវិធីដែលអនុវត្តមិនទាន់ចប់នៅក្នុងឆ្នាំថវិកា ត្រូវដាក់បញ្ចូលដើម្បីបន្តអនុវត្តនៅក្នុងគម្រោងថវិកាឆ្នាំបន្ទាប់ ដែលការគ្រោងចំណាយនេះស្ថិតនៅក្នុងកម្មវិធីវិនិយោគប្រចាំឆ្នាំដែលក្រុមប្រឹក្សាឃុំ សង្កាត់បានពិនិត្យ និងអនុម័តចុងក្រោយបំផុត។

កម្មវិធីវិនិយោគប្រចាំឆ្នាំ ដែលទទួលបានហិរញ្ញប្បទានគាំទ្រក្រោយពេលដែលមានគម្រោងថវិកាត្រូវបានអនុម័ត គឺជាកម្មវត្ថុនៃការកែសម្រួលគម្រោងថវិកាទៅតាមនីតិវិធីដូចគ្នាទៅនឹងការរៀបចំ និងអនុម័តថវិកាដំបូង និងត្រូវធ្វើប្រតិភូកម្មបន្ថែមដោយអភិបាលនៃគណៈអភិបាលរាជធានី សម្រាប់រដ្ឋបាលសង្កាត់ចំណុះរដ្ឋបាលរាជធានី និងអភិបាលនៃគណៈអភិបាលក្រុង សម្រាប់រដ្ឋបាលសង្កាត់ចំណុះរដ្ឋបាលក្រុង ឬបញ្ចូលទៅក្នុងគម្រោងនៃថវិកាឆ្នាំបន្ទាប់។

**មាត្រា១១.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវគណនា និងជូនដំណឹងជាផ្លូវការនៅមុនដំណាច់ខែមិថុនានៃឆ្នាំថវិកាអំពីចំនួនធនធានវិភាជន៍ដែលរដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវទទួលបានសម្រាប់ឆ្នាំបន្ទាប់ក្នុងក្របខ័ណ្ឌនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា១២.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសិទ្ធិចាត់ចែងធ្វើការផ្ទៀងផ្ទាត់ដោយធ្វើអធិការកិច្ចហិរញ្ញវត្ថុ ឬការត្រួតពិនិត្យហិរញ្ញវត្ថុតាមការចាំបាច់ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងបទប្បញ្ញត្តិច្បាប់ដែលមានការពាក់ព័ន្ធជាធរមាន។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**មាត្រា១៣-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក អភិបាលនៃគណៈអភិបាលក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ថ្ងៃព្រហស្បតិ៍ ១១ រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

<u>**កន្លែងទទួល÷**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ